**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ: ៤២ អយក.សណ**

# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់ក្រោយឧត្តមសិក្សា និងប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់ឧត្តមសិក្សាទៅសិក្សានៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឆ្នាំសិក្សា២០១៤-២០១៥

**យោង** : -ពិធីសារស្តីពីកិច្ចសហប្រតិបត្តិការអប់រំ សម្រាប់ឆ្នាំ ២០១១ ដល់ ២០១៥ រវាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអប់រំ និងបណ្តុះបណ្តាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១ ។

-ផែនការសហប្រតិបត្តិការសម្រាប់ឆ្នាំ២០១៤ រវាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអប់រំ និងបណ្តុះបណ្តាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៣ ។

**ក្រសួងអប់រំ យុវជន និងកីឡា**

សូមជូនដំណឹងដល់សាធារណជនទាំងពីរភេទថាក្នុងឆ្នាំសិក្សា២០១៤-២០១៥នេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់ក្រោយឧត្តមសិក្សាចំនួន **២០កន្លែង** និងប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រចំនួន **៦០កន្លែង** ទៅសិក្សានៅសាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវបានកំណត់ដូចខាងក្រោម :

**I-ថ្នាក់ក្រោយឧត្តមសិក្សា:** ថ្នាក់បណ្ឌិត (Ph.D) និងថ្នាក់អនុបណ្ឌិត (Master) **២០កន្លែង**

**ក.លក្ខខណ្ឌនៃការចុះឈ្មោះជាបេក្ខភាព**

បេក្ខជនទាំងពីរភេទត្រូវ :

-មានសញ្ជាតិខ្មែរ

-ជានិស្សិតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ឬថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មកពីសាធារណរដ្ឋសង្គមនិយមវៀតណាម

-មានអាយុមិនលើសពី ៤០ ឆ្នាំគិតត្រឹមខែកញ្ញា ឆ្នាំ ២០១៤

-មានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និង សតិបញ្ញា

**ខ.សំណុំឯកសារត្រូវបំពេញ**

| | | |
|---|---|---|
| -ពាក្យសុំអាហារូបករណ៍ | ០១ច្បាប់ | "មានគំរូ" |
| -ជីវប្រវត្តិសង្ខេប | ០១ច្បាប់ | "មានគំរូ" |
| -កិច្ចសន្យា | ០១ច្បាប់ | "មានគំរូ" |



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៣ /២១៧ ២៥៣ /៤២៦ ៥៤១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

-សញ្ញាបត្រទទួលបាន ( ជាភាសាវៀតណាម ឬភាសាអង់គ្លេស)

-រូបថត ៤ X ៦ ( ពណ៌ធម្មជាតិទើបថតថ្មី)　　　　　០៤សន្លឹក

-លិខិតឧទ្ទេសនាមពីថ្នាក់ក្រសួង ˝ចំពោះបេក្ខជនជាមន្ត្រីរាជការ˝

-វិញ្ញាបនបត្រពិនិត្យកាយសម្បទា ˝០២សន្លឹក˝ បំពេញក្រោយពេលដែលសាមីជនត្រូវបានជ្រើសរើសរួច ។

**គ.ការជ្រើសរើស**

គណៈកម្មការក្រសួងអប់រំ យុវជន និងកីឡាជ្រើសរើស ។

**ឃ.កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ដែលមានអាស័យដ្ឋានអគារលេខ២៣ ផ្លូវ៣៦០ ខាងកើតស្តានីយ៍ទូរទស្សន៍អប្សរាប្រហែល ៥០ម៉ែត្រ ។

**II-ថ្នាក់បរិញ្ញាបត្រៈ ចំនួន ៦០កន្លែងៈ**

**១.លក្ខខណ្ឌនៃការចុះឈ្មោះជាបេក្ខភាព**

បេក្ខជនទាំងពីរភេទត្រូវ :

-មានសញ្ជាតិខ្មែរ

-មានអាយុមិនលើសពី ៣០ ឆ្នាំគិតត្រឹមខែកញ្ញា ឆ្នាំ២០១៤

-មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ( ក្នុងឆ្នាំសិក្សា២០១១-២០១២ ឬ ២០១២-២០១៣)

-មានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និង សតិបញ្ញា

**២.សំណុំឯកសារត្រូវបំពេញ**

| | | |
|---|---|---|
| -ពាក្យសុំអាហារូបករណ៍ | ០១ច្បាប់ | ˝មានគំរូ˝ |
| -ជីវប្រវត្តិសង្ខេប | ០១ច្បាប់ | ˝មានគំរូ˝ |
| -កិច្ចសន្យា | ០១ច្បាប់ | ˝មានគំរូ˝ |

-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិច្បាប់ថតចម្លង ឬសញ្ញាបត្រមានតម្លៃស្មើ ០១ច្បាប់ ( មានបញ្ជាក់ពីសាលារាជធានី-ខេត្ត) ដោយភ្ជាប់ច្បាប់ដើមមកជាមួយដើម្បីផ្ទៀងផ្ទាត់

-រូបថត ៤ X ៦ ( ពណ៌ធម្មជាតិទើបថតថ្មីរយៈពេល០៣ខែចុងក្រោយ)　　　០៤សន្លឹក

-លិខិតឧទ្ទេសនាមពីថ្នាក់ក្រសួង　　　　　　˝ចំពោះបេក្ខជនជាមន្ត្រីរាជការ˝

-វិញ្ញាបនបត្រពិនិត្យកាយសម្បទា ˝០២សន្លឹក˝ បំពេញក្រោយពេលប្រឡងជាប់

**៣-កាលបរិច្ឆេទ និង ទីកន្លែងទទួលពាក្យ**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅរហូតដល់**ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤** វេលាម៉ោង **១៦ម៉ោង០០** នៅការិយាល័យអាហារូបករណ៍ និង កម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ដែលមានអាស័យដ្ឋានអគារលេខ ២៣ ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ( ខាងកើតស្ថានីយទូរទស្សន៍អប្សរាប្រហែល៥០ម៉ែត្រ ) ។

**៣-កាលបរិច្ឆេទប្រឡង**

**-ប្រឡងនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៤** ( មណ្ឌលប្រឡង នឹងជម្រាបជូនពេលក្រោយ ) ។

**៤-វិញ្ញាសាប្រឡងមាន**

| | |
|---|---|
| -វប្បធម៌ទូទៅ : | រយៈពេល ០១ ម៉ោង ៣០ នាទី |
| -រូបវិទ្យា : | រយៈពេល ០១ ម៉ោង |
| -គីមីវិទ្យា : | រយៈពេល ០១ ម៉ោង |
| -គណិតវិទ្យា : | រយៈពេល ០១ ម៉ោង ៣០ នាទី |

ចំពោះព័ត៌មានលម្អិតផ្សេងៗបេក្ខជនអាចទាក់ទងការិយាល័យអាហារូបករណ៍ និងកម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ អគារលេខ២៣ ផ្លូវ៣៦០សង្កាត់បឹងកេងកង១ ខណ្ឌចំការមន( ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាប្រហែល៥០ម៉ែត្រ ) ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១៤

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

យក់ ប៊ុយ

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងមហាផ្ទៃ

-ស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា

*" ដើម្បីជូនជ្រាបជាពត៌មាន "*

-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-សាលាខេត្ត-រាជធានី

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-រាជធានី

*" ដើម្បីជួយផ្សព្វផ្សាយ និងខ្ទេសទាម "*

-កាលប្បវត្តិ-ឯកសារ-នា ទវអ.